**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
**ជាតិ សាសនា ព្រះមហាក្សត្រ**
***Nation Religion King***

**ក្រសួងពាណិជ្ជកម្ម**
MINISTRY OF COMMERCE
**អគ្គនាយកដ្ឋាន សេវាពាណិជ្ជកម្ម**
GENERAL DIRECTORATE OF TRADE SUPPORT SERVICES
**នាយកដ្ឋាន កម្មសិទ្ធិបញ្ញា**
DEPARTMENT OF INTELLECTUAL PROPERTY

# ការកត់ត្រាលើការកែតម្រូវសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ម្រេចកំពត"

# RECORDAL OF AMENDMENT OF BOOK OF SPECIFICATION OF GEOGRAPHICAL INDICATION "KAMPOT PEPPER"

យោងតាមលទ្ធផលនៃការត្រួតពិនិត្យ លើពាក្យស្នើសុំកត់ត្រាលើការកែតម្រូវសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"ម្រេចកំពត"** ហើយ ដែលបានដាក់ពាក្យ នៅថ្ងៃទី:
Based on the result of the examination of the Request for Recordal of Amendment of Book of Specification of Geographical Indication **"Kampot Pepper"** filed: May 26, 2023

លេខចុះបញ្ជីដើម និង ជំពូក: **KH/GI/00001/10** in class: 30
Original Registration No. and Class:

**សូមបញ្ជាក់ថា**
**HEREBY CERTIFY**

សៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"ម្រេចកំពត"** ដែលបានស្នើសុំកែតម្រូវ:
that the Book of Specification of **"Kampot Pepper"** requested for amendment:

សូមពិនិត្យមើលឧបសម្ព័ន្ធ នៅខាងក្រោយនៃលិខិតកត់ត្រា និងតម្កល់នេះ។
Please see attached at behind of this Recordal of Amendment.

ម្ចាស់ម៉ាក Owner : **Kampot Pepper Promotion Association**
អាសយដ្ឋាន Address : Angkor Chey I Village, Damnak Kantuot Khang Tbaung Commune, Kampong Trach District, Kampot Province, Cambodia

អាសយដ្ឋានទំនាក់ទំនងក្នុងប្រទេស:
Local Address for Service:

ត្រូវបានកត់ត្រាក្នុងបញ្ជីម៉ាក របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មរួចហើយ។
have been recorded in the Register of Marks of the Department of Intellectual Property Rights, Ministry of Commerce.

ដើម្បីជាសក្ខីភាព ខ្ញុំសូមចុះហត្ថលេខា និង ប្រថាប់ត្រានៃក្រសួងពាណិជ្ជកម្មថ្ងៃនេះ
In witness whereof, I have hereunto affixed my hand and the stamp of the Ministry of Commerce today.

2023-11810

23 JUN 2023

**អ៊ុក-ប្រជា**

**១- ចំណុច ៤៖** ការពិពណ៌នាអំពីផលិតផល

បានបន្ថែមមុខទំនិញសម្គាល់ភូមិសាស្ត្រមួយចំនួនលើប្រភេទ **ម្រេចស ម្រេចក្រហម** និង **ម្រេចខ្ចី** ដូចខាងក្រោម៖

- **ម្រេចស៖** ម្រេចសម៉ដ្ឋ
- **ម្រេចក្រហម៖** ម្រេចក្រហមម៉ដ្ឋ ជ្រក់ម្រេចក្រហមស្ងួត (ជាគ្រាប់រាយ ឬម៉ដ្ឋ) ជ្រក់ម្រេចក្រហមសើម និង ជ្រក់ម្រេចក្រហមស្ងួត
- **ម្រេចខ្ចី៖** ជ្រក់ម្រេចខ្ចីស្ងួត ជ្រក់ម្រេចខ្ចីសើម និងម្រេចខ្ចីសម្ងួត (កែច្នៃពីម្រេចខ្ចីស្រស់ ឬជ្រក់ម្រេចខ្ចី)

**២- ចំណុច ៦.១.៣៖** ការដាំដុះ

មិនអនុញ្ញាតឱ្យប្រើជន្លង់ធ្វើពី **ឥដ្ឋ** សម្រាប់ដាំដុះ **"ម្រេចកំពត"** ឡើយ។

**៣- ចំណុច ៦.១.៥៖** ការគ្រប់គ្រងកត្តាចង្រៃ

ផលិតករត្រូវប្រើប្រាស់វិធានការរូបសាស្ត្រ ជីវសាស្ត្រ ឬថ្នាំសម្លាប់សត្វល្អិត ដែលផលិតដោយខ្លួនឯងពីរុក្ខជាតិ ឬមេីម រុក្ខជាតិ ដែលមិនប៉ះពាល់ដល់សុខភាព។

**៤- ចំណុច ៦.២.១៖** ទំនិញសម្គាល់ភូមិសាស្ត្រ **ម្រេចខ្ចី ម្រេចខ្មៅ ម្រេចក្រហម** និង **ម្រេចស**

ផលិតករអាចប្រមូលផលម្រេចខ្មៅ និងម្រេចក្រហម ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែកក្កដា គឺត្រូវប្រមូលផល នៅពេលដែលក្បាលសណ្តង់មានពណ៌លឿង រហូតដល់មានទុំខ្លះៗ។ ផលិតករអាចប្រមូលផលម្រេចជាកួរ ឬជាគ្រាប់។ ម្រេចត្រូវបានប្រមូលផលច្រើនដង នៅក្នុងរដូវប្រមូលផល។

**៥- ចំណុច ៦.២.៣៖** ការកែច្នៃ និងវេចខ្ចប់

- **សុពលភាពម្រេចកំពត៖** ម្រេចខ្មៅ ម្រេចក្រហម និងម្រេចស អាចប្រើប្រាស់បានក្នុងរយៈពេលយ៉ាងយូរ ៥ឆ្នាំ ដោយគិតចាប់ពីរដូវប្រមូលផលម្រេចកំពត ត្រូវបានបញ្ចប់ (ថ្ងៃទី៣១ ខែកក្កដា)។
- **សុពលភាពម្រេចខ្មៅម៉ដ្ឋ ម្រេចក្រហមម៉ដ្ឋ និងម្រេចសម៉ដ្ឋ៖** អាចប្រើប្រាស់បានយ៉ាងយូរ ១ឆ្នាំ បន្ទាប់ពីកិនរួច
- **សុពលភាពម្រេចខ្ចីស្រស់ត្រាំទឹកអំបិល ឬទឹកខ្មេះ ជ្រក់ម្រេចខ្ចី និងជ្រក់ម្រេចក្រហម (សើម) និង (ស្ងួត)៖** អាចប្រើប្រាស់បានយ៉ាងយូរបំផុត ២ឆ្នាំ បន្ទាប់ពីការវេចខ្ចប់
- **សុពលភាពម្រេចខ្ចីជ្រក់សម្ងួត និងម្រេចក្រហមជ្រក់សម្ងួត៖** អាចប្រើប្រាស់បានយ៉ាងយូរបំផុត ៣ឆ្នាំ បន្ទាប់ពីការ វេចខ្ចប់ និងការពិពណ៌នាអំពីដំណើរការនៃការកែច្នៃម្រេចជ្រក់ ដូចមានចែងក្នុងសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ទំនិញ។
- ការវេចខ្ចប់ **"ម្រេចកំពត"** អាចធ្វើនៅតំបន់ណាក៏បានទាំងនៅក្នុងប្រទេសកម្ពុជា ឬអន្តរជាតិ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅបន្ទុក
# ទំនិញសម្គាល់ភូមិសាស្ត្រ "ម្រេចកំពត"

រៀបចំដោយ៖ **សមាគមលើកកម្ពស់ម្រេចកំពត**

ខេត្តកំពត ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣

# សៀវភៅបន្ទុក "ម្រេចកំពត"

## ១. អ្នកស្នើសុំ៖ សមាគមលើកកម្ពស់ម្រេចកំពត

- ចុះបញ្ជីនៅក្រសួងមហាផ្ទៃលេខៈ ២៩៣ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨
- អាសយដ្ឋានៈ ភូមិអង្គរជ័យ១ ឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត ប្រទេសកម្ពុជា
- ទូរសព្ទលេខៈ ០៩២ ៧៥២ ៥៧២ ឬ ០៩២ ៦១៨ ០១១
- អ៊ីម៉ែលៈ kppa2008@yahoo.com / kppa2008@gmail.com

## ២. ឈ្មោះផលិតផល

- ភាសាខ្មែរ៖ **ម្រេចកំពត**
- ភាសាអង់គ្លេស៖ Kampot Pepper
- ភាសាបារាំង៖ **Poivre de Kampot** និង
- ភាសាផ្សេងទៀតដែលមានអត្ថន័យដូចគ្នានឹងពាក្យ "**ម្រេចកំពត**" ដែលរួមមានប្រភេទម្រេច៖
  - ម្រេចកំពតខ្មៅ ជាភាសាអង់គ្លេស "Kampot black pepper" និងជាភាសាបារាំង "Poivre noir de Kampot"
  - ម្រេចកំពតក្រហម ជាភាសាអង់គ្លេស "Kampot red pepper" និងជាភាសាបារាំង "Poivre rouge de Kampot"
  - ម្រេចកំពតស ជាភាសាអង់គ្លេស "Kampot white pepper" និងជាភាសាបារាំង "Poivre blanc de Kampot"
  - ម្រេចកំពតខ្ចី ជាភាសាអង់គ្លេស "Kampot green pepper" និងជាភាសាបារាំង "Poivre vert de Kampot"

## ៣. ប្រភេទផលិតផល

Spice, Pepper (Berries of *Piper nigrum L.*)

## ៤. ការពិពណ៌នាអំពីផលិតផល

"**ម្រេចកំពត**" មានរសជាតិហិរ (ប៉ុន្តែមិនរលាកមាត់) និងមានក្លិនឈ្ងុយ។ គេអាចសម្គាល់ "**ម្រេចកំពត**" បានតាមរយៈរសជាតិហិរ និងមានក្លិនពិសេសប្លែកគេរបស់វា។

ប្រភេទ "**ម្រេចកំពត**" ដែលផលិត និងធ្វើអាជីវកម្មនៅលើទីផ្សារ រួមមាន៖

- ម្រេចខ្មៅ ជាគ្រាប់រាយ ឬម៉ដ្ឋ
- ម្រេចក្រហម ជាគ្រាប់រាយ ឬម៉ដ្ឋ ឬជ្រក់
- ម្រេចស ជាគ្រាប់រាយ ឬម៉ដ្ឋ
- ម្រេចបៃតង ឬម្រេចខ្ចី ជាគ្រាប់រាយ និងចង្កោម ឬជ្រក់



ម្រេចខ្មៅ



ម្រេចក្រហម



ម្រេចស



ម្រេចបៃតង ឬម្រេចខ្ចី

**តារាងទី ១: ការពិពណ៌នាអំពីប្រភេទ "ម្រេចកំពត"**

| ប្រភេទ | ទម្រង់ | ទំហំ និងចំណុះ | ពណ៌ | ក្លិន | រសជាតិ | ការអនុគ្រោះ |
|---|---|---|---|---|---|---|
| ម្រេចខ្មៅ | គ្រាប់រាយ (ស្ងួត) | ទំហំ ∅ ≥ ៤មម<br>ចំណុះ ≥ ៥៧០ក្រ/លីត្រ | - ខ្មៅងងឹត<br>- ខ្មៅ<br>- ខ្មៅត្នោត ឬខ្មៅប្រផេះ | គ្រាប់ម្រេចមានក្លិនឆួលមធ្យម | | - គ្រាប់មានទំហំខុសគ្នាយ៉ាងច្រើន ៥ %<br>- ពណ៌មានភាពខុសគ្នាតិចជាង ២% |
| | ម៉ដ្ឋ (កិនពីគ្រាប់រាយស្ងួត) | ជាម្សៅ ប៉ុន្តែមិនម៉ដ្ឋខ្លាំង ហើយមានបំណែកតូចៗ ដែលអាចមើលឃើញ | ពណ៌ប្រផេះងងឹត មានចំណុចខ្មៅៗ | ក្លិនឆួលខ្លាំងបានយូរ | | |
| ម្រេចក្រហម | គ្រាប់រាយ(ស្ងួត) | ទំហំ ∅ ≥ ៤មម<br>ចំណុះ ≥ ៥៧០ក្រ/លីត្រ | ក្រហមត្នោត ឬក្រហមក្រម៉ៅ | គ្រាប់ម្រេចមានក្លិនឆួលមធ្យម | | - គ្រាប់មានទំហំខុសគ្នាយ៉ាងច្រើន ៥ %<br>- ពណ៌មានភាពខុសគ្នាតិចជាង ២% |
| | ម៉ដ្ឋ (កិនពីគ្រាប់រាយស្ងួត) | ជាម្សៅ ប៉ុន្តែមិនម៉ដ្ឋខ្លាំង ហើយមានបំណែកតូចៗ ដែលអាចមើលឃើញ | ក្រហមស្រាលលាយស | ក្លិនឆួលខ្លាំងបានយូរ | - ហឹរ<br>- ផ្អែមតិចៗ | |
| | ជ្រក់ម្រេចស្ងួតជាគ្រាប់រាយ ឬម៉ដ្ឋ | ជ្រក់ម្រេចម៉ដ្ឋ៖គ្រាប់ម្រេចត្រូវបានបំបែកជាបំណែកតូចៗ តែមិនម៉ដ្ឋ | ក្រហមក្រម៉ៅលាយស | ឈ្ងុយ | - ប្រៃ<br>- ផ្អែមតិចៗ<br>- ហឹរ | |

| ប្រភេទ | ទម្រង់ | ទំហំ និងចំណុះ | ពណ៌ | ក្លិន | រសជាតិ | ការអនុគ្រោះ |
|---|---|---|---|---|---|---|
| | | ជ្រក់ម្រេចគ្រាប់៖<br>ទំហំ ∅ ≥ ៤មម | ក្រហមប្រផេះ | ក្លិនក្រអូប ជូរប្រហើរ និងឈ្ងុយ | - ប្រៃ<br>- ហិរ<br>- ផ្អែមតិចៗ | ស្រួយ |
| | ជ្រក់សើម ជាគ្រាប់រាយ | ទំហំ ∅ ≥ ៤មម | ក្រហមស្រាល | ក្លិនម្រេចស្រាល | - ហិរ<br>- ប្រៃ<br>- ផ្អែមតិចៗ | |
| | ជ្រក់សម្ងួត ជាគ្រាប់ | ទំហំ ∅ ≥ ៤មម | ក្រហមស្រាល | ក្លិនម្រេចស្រាល | - ហិរ<br>- ប្រៃ<br>- ផ្អែមតិចៗ | |
| ម្រេចស | គ្រាប់រាយ (ស្ងួត) | ទំហំ ∅ ≥ ៣មម<br>ចំណុះ ≥ ៦០០ក្រ/លីត្រ | - សប្រផេះ លឿងតិចៗ ឬសំបកសណ្តែកសៀង<br>- ពណ៌សពីធម្មជាតិដោយមិនមានបន្ថែមផលិតផល ឬសារធាតុកែប្រែពណ៌ | មានក្លិនឆួលមធ្យម | | - គ្រាប់មានទំហំខុសគ្នាយ៉ាងច្រើន ៥%<br>- ពណ៌មានភាពខុសគ្នាតិចជាង ២% |
| | ម៉ដ្ឋ (កិនពីគ្រាប់រាយស្ងួត) | ជាម្សៅ ប៉ុន្តែមិនម៉ដ្ឋខ្លាំង ហើយមានបំណែកតូចៗដែលអាចមើលឃើញ | សប្រផេះ | មានក្លិនឆួលខ្លាំង បានយូរ និងឈ្ងុយប្រេងម្រេច | ហិរខ្លាំង | |
| ម្រេចបៃតង ឬម្រេចខ្ចី | គ្រាប់ស្រស់នៅជាប់កួរទាំងមូល | កួរនីមួយៗមានចំនួនយ៉ាងតិច ១០គ្រាប់<br>ទំហំគ្រាប់ ∅ ≥ ៣មម | បៃតងចាស់ | - ក្លិនស្មៅស្រស់លាយក្លិនម្រេច<br>- មិនមានក្លិនឆួលពេលនៅជាគ្រាប់<br>- ពេលម៉ដ្ឋមានក្លិនឆួលខ្លាំងប៉ុន្តែឆាប់បាត់ក្លិន<br>- មិនមានក្លិន៖<br>. ធូលី<br>. ផ្សិត | | - គ្រាប់មានទំហំខុសគ្នាយ៉ាងច្រើន ៥%<br>- ពណ៌មានភាពខុសគ្នាតិចជាង ២% |
| | ជ្រក់ស្ងួត៖ គ្រាប់ម្រេចខ្ចី ប្រឡាក់ផ្កាអំបិល ឬ អំបិលម៉ដ្ឋ ឬទឹកខ្មេះ | ទំហំគ្រាប់ ∅ ≥ ៣មម | - ខ្មៅ<br>- ខ្មៅស្រអាប់<br>- ប្រផេះស្រាលសណ្តែកបាយ | - ក្លិនម្រេចប្រហើរតិចៗ<br>- មិនឆួល<br>- ក្លិនជូរឆួល<br>- ក្លិនជ្រក់តិចៗ | - ប្រៃល្មម ទៅប្រៃ<br>- ហិរ<br>- ជូរតិចៗ<br>- ផ្អែមតិចៗ | - ស្រួយ<br>- ទន់ |
| | ជ្រក់ម្រេចខ្ចី (សើម)៖ គ្រាប់ម្រេចខ្ចី ប្រឡាក់ផ្កាអំបិល ឬ អំបិលម៉ដ្ឋ ឬត្រាំទឹកខ្មេះ | ទំហំគ្រាប់ ∅ ≥ ៣មម | - បៃតងស្រគាំ<br>- បៃតងស្រស់រាងលឿង<br>- សណ្តែកបាយ | - ក្លិនម្រេចឈ្ងុយប្រហើរ<br>- ក្លិនជូរជ្រក់<br>- ក្លិនដូចទឹកឃ្មុំ | - ហិរ<br>- មានខ្ទិះឆ្ងាញ់<br>- ប្រៃល្មម<br>- ជូរតិចៗ<br>- ល្វីងតិចៗ | - ស្រួយ<br>- ទន់ |

| ប្រភេទ | ទម្រង់ | ទំហំ និងចំណុះ | ពណ៌ | ក្លិន | រសជាតិ | ការអនុគ្រោះ |
|---|---|---|---|---|---|---|
| | ម្រេចខ្ចីសម្ងួតៈ គ្រាប់ម្រេចខ្ចីស្ងួត ឬគ្រាប់ម្រេចខ្ចីជ្រក់ស្ងួត | ទំហំគ្រាប់ ∅ ≥ ៣មម | - បៃតងលឿង សណ្តែកបាយ | ឈ្ងុយម្រេច | ហិរតិចៗ | ស្រួយ |

ម្រេចដែលមានចេញវិញ្ញាបនបត្របញ្ជាក់ត្រូវលក់ឱ្យអតិថិជនចុងក្រោយដោយដាក់ស្លាកយីហោ និងវេចខ្ចប់ឱ្យបានត្រឹមត្រូវដើម្បីជៀសវាងការក្លែងបន្លំ។

## ៥. តំបន់ភូមិសាស្ត្រ និងភស្តុតាងបញ្ជាក់ពីប្រភពផលិតផល

### ៥.១ តំបន់ភូមិសាស្ត្រ

តំបន់ដែលអាចផលិត **"ម្រេចកំពត"** បាន លុះត្រាតែស្ថិតនៅក្នុងស្រុក ឬក្រុងដូចខាងក្រោម៖

- ស្រុកកំពង់ត្រាច ស្រុកដងទង់ ស្រុកទឹកឈូរ ស្រុកឈូក និងក្រុងកំពត ខេត្តកំពត
- ក្រុងកែប និងស្រុកដំណាក់ចង្អើរ ខេត្តកែប

**តំបន់ផលិតកម្ម** “ម្រេចកំពត”




**ចំណាំ៖** ដើម្បីទទួលបានសិទ្ធិផលិត **"ម្រេចកំពត"** ប្រតិបត្តិករត្រូវមានដីដាំដុះម្រេចនៅក្នុងតំបន់ដែលបានកំណត់នៅក្នុងសៀវភៅបន្ទុក ហើយដីទាំងនោះត្រូវបំពេញលក្ខខណ្ឌមានចែងនៅក្នុង **ចំណុចទី ៦** ខាងក្រោម។

### ៥.២ ភស្តុតាងបញ្ជាក់ពីប្រភពដើម

ដើម្បីផលិត និងធ្វើអាជីវកម្មម្រេចដែលមានឈ្មោះថា **"ម្រេចកំពត"** ប្រតិបត្តិករត្រូវចុះឈ្មោះនៅក្នុង "**សមាគមលើកកម្ពស់ម្រេចកំពត"** ដើម្បីក្លាយជាសមាជិកសមាគម។ ប្រតិបត្តិករទាំងអស់ត្រូវប្រកាស និងកត់ត្រាពីបរិមាណម្រេចដែលផលិត ទិញចូល និងលក់ចេញ។ ប្រព័ន្ធស្វែងរកតឹកដានត្រូវបានបង្កើត ដើម្បីតាមដានផលិតផលតាំងពីពេលផលិតរហូតដល់លក់នៅលើទីផ្សារ។

ត្រូវចាប់សំណាកដោយចៃដន្យដើម្បីពិនិត្យមើលលើការអនុវត្តតាមនៃផលិតផល **"ម្រេចកំពត"** ជាមួយនឹងលក្ខណៈដែលបានកំណត់ថាជាលក្ខណៈពិសេសប្លែកគេនៃ **"ម្រេចកំពត"** នៅចំណុចទី ៤ ដែលរៀបរាប់អំពី "**ការពិពណ៌នាពីផលិតផល**"។

## ៦. បច្ចេទេសផលិត

### ៦.១ ការគ្រប់គ្រងដំណាំ

#### ៦.១.១ ដីដាំដុះ

ចំការម្រេចត្រូវតែស្ថិតនៅលើដីទួល ឬនៅតាមជើងភ្នំ។ ចំការម្រេចទាំងនោះត្រូវរៀបចំនៅលើប្រភេទដីមានថ្មបាយក្រៀមមានលាយគ្រួស ឬថ្ម និងដីខ្សាច់មិនជាំទឹក។ ចំពោះស្ថានភាពដីផ្សេងទៀតដូចជា៖ ដីវាលរាប និងខ្ពង់រាប គេអាចធ្វើចំការម្រេចនៅក្នុងករណីដីនោះងាយប្រោះទឹក ឬលើដីជំរាលពីធម្មជាតិ។ ត្រូវរៀបចំប្រឡាយទឹកព័ន្ធជុំវិញចំការម្រេចក្នុងជម្រៅយ៉ាងតិច ០.៨០ម៉ែត្រ ដើម្បីសម្រោះទឹក។



ប្រភេទដីដាំម្រេច

#### ៦.១.២ ពូជ

**"ម្រេចកំពត"** ផលិតចេញពី៖ ពូជកំចាយ និងពូជលំពុង (បេឡាងទង់) ដែលប្រជាកសិករនាំគ្នាហៅថាពូជ "**ស្លឹកតូច**" និងពូជ "**ស្លឹកធំ**" ហើយពូជទាំងនេះ ត្រូវស្ថិតក្នុងតំបន់ផលិតកម្ម **"ម្រេចកំពត"**។



ពូជស្លឹកតូច



ពូជស្លឹកធំ

### ៦.១.៣ ការដាំដុះ:

ដាំជាជួរ ហើយពីគុម្ពមួយទៅគុម្ពមួយមានចន្លោះយ៉ាងតិច ១.៨០ម៉ែត្រ ដើម្បីងាយស្រួលដល់ការដាក់ជីធម្មជាតិ (លាមកសត្វ) និងជីផៅ។ ផលិតករត្រូវសង់រោងដើម្បីផ្តល់ម្លប់ដល់ម្រេចចាប់ពីពេលដាំដំបូង រហូតដល់មានអាយុយ៉ាងតិច ៣ឆ្នាំ។ មិនអនុញ្ញាតឱ្យប្រើជន្លង់ធ្វើពីឥដ្ឋសម្រាប់ដាំម្រេចកំពតឡើយ។



**ការដាំម្រេចជាជួរក្នុងចន្លោះគុម្ពយ៉ាងតិច ១.៨០ម៉ែត្រ**

### ៦.១.៤ ការថែទាំ

ប្រើតែជីសរីរាង្គ (ដាក់ជីផៅ ជីលាមកសត្វ សំបកក្តាម-បង្គា និងជីធម្មជាតិផ្សេងទៀតដែលផ្សំខ្លួនឯង)។ ត្រូវដាក់ជីយ៉ាងតិច ១ដង ក្នុងមួយឆ្នាំៗ នៅចន្លោះខែឧសភា និងខែកក្កដា ប៉ុន្តែនៅឆ្នាំទី ៤ អាចដាក់ ឬមិនដាក់ក៏បាន។

**ស្រោចស្រពនៅរដូវប្រាំង:** ចំការម្រេចត្រូវមានទីតាំងនៅមិនឆ្ងាយពីប្រភពទឹក ដើម្បីសម្រួលដល់ការស្រោចស្រព។

ប្រសិនបើកម្រិតជីនៅមិនទាន់គ្រាប់គ្រាន់ដើម្បីការពារម្រេចទល់នឹងទឹកឡើងនោះទេ ត្រូវដាក់ជីផៅយ៉ាងតិច ១ដង ក្នុងរយៈពេល ២ឆ្នាំ។ ចាប់ពីខែមិថុនា ដល់ខែធ្នូ ផលិតករត្រូវពូនជ្រោយដីនៅជុំវិញគល់ ដើម្បីបំបែកដីធ្វើឱ្យទឹកជ្រាបបានល្អ និងសម្លាប់សត្វល្អិតចង្រៃនៅក្នុងដីដូចជាកណ្តៀរជាដើម។ ហាមប្រើប្រាស់ថ្នាំពុលគីមីសម្លាប់ស្មៅ។



**ការដាក់ជីធម្មជាតិ**



**ការដាក់ជីផៅ**

### ៦.១.៥ ការគ្រប់គ្រងកត្តាចង្រៃ

ក្នុងការគ្រប់គ្រងកត្តាចង្រៃ ផលិតករត្រូវប្រើប្រាស់វិធានការរូបសាស្ត្រ ជីវសាស្ត្រ ឬថ្នាំសម្លាប់សត្វល្អិតដែលផលិតដោយខ្លួនឯងពីរុក្ខជាតិ ឬមីមរុក្ខជាតិ ដែលមិនប៉ះពាល់ដល់សុខភាព។

## ៦.២ ការប្រមូលផល និងក្រោយប្រមូលផល

### ៦.២.១ ផលិតផល

**ម្រេចខ្មៅ និងម្រេចក្រហម**

ផលិតករអាចប្រមូលផលម្រេចខ្មៅ និងម្រេចក្រហម **ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែកក្កដា** គឺត្រូវប្រមូលផលនៅពេលដែលក្បាលសណ្តង់មានពណ៌លឿង រហូតដល់មានទុំខ្លះៗ។ ផលិតករអាចប្រមូលផលម្រេចជាក្ួរ ឬជាគ្រាប់។ ម្រេចត្រូវបានប្រមូលផលច្រើនដង នៅក្នុងរដូវប្រមូលផល។

ម្រេចក្រហមផលិតចេញពីការប្រឡេះគ្រាប់ម្រេចទុំពីក្ួរម្រេច នៅពេលកំពុងប្រមូលផល ឬក្រោយពេលប្រមូលផល ផលិតករជ្រើសរើសម្រេចទុំចេញពីក្ួរដែលបានប្រមូលផលរួច។

**ម្រេចស**

ម្រេចសផលិតចេញពីម្រេចទុំ។ ត្រូវយកម្រេចទុំទៅស្រុះទឹកពុះយ៉ាងយូរ ៥នាទី និងត្រាំទឹកត្រជាក់យ៉ាងយូរ ៤៨ម៉ោង បន្ទាប់មកសម្អាតសំបកចេញដើម្បីទទួលបានម្រេចស។

**ម្រេចបៃតង ឬម្រេចខ្ចី**

ម្រេចខ្ចីអាចប្រមូលផលបាននៅគ្រប់រដូវ។ ម្រេចខ្ចីអាចលក់ និងប្រើប្រាស់បានទាំងនៅស្រស់ៗ។ ម្រេចស្រស់អាចប្រឡេះដាក់ត្រាំទឹកអំបិល ឬទឹកខ្មេះ។

### ៦.២.២ បច្ចេទេសក្រោយប្រមូលផល និងការស្តុកម្រេច

ត្រូវលាងសម្អាតសម្ភារៈប្រើប្រាស់ដាក់ម្រេចនៅពេលប្រមូលផលម្រេចនឹងសាប៊ូឱ្យបានស្អាត។ ត្រូវលាងសម្អាតសរីរាង្គទាំងឡាយណាដែលប៉ះផ្ទាល់នឹងម្រេចជាមួយនឹងសាប៊ូនៅមុនពេលប្រមូលផល និងប្រឡេះគ្រាប់ម្រេច។ ធុងទឹក និងសាប៊ូត្រូវរៀបចំដាក់នៅចំការម្រេចនៅរដូវប្រមូលផល។

**ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៥** ផលិតករត្រូវហាលម្រេចលើស្បៃនីឡុង កន្ទេល ឬតង់ នៅលើកម្រាលបេតុងស៊ីម៉ង់ត៍ ឬនៅលើធ្នើខ្ពស់ផុតពីដី។ យើងត្រូវសម្លាប់មេរោគ និងសម្អាតស្បៃនីឡុង កន្ទេល ឬតង់ ឱ្យបានស្អាតនៅមុនរដូវប្រមូលផល។ មិនត្រូវឱ្យសត្វចូលទៅទីកន្លែងហាលម្រេចបាននោះទេ។

នៅក្នុងដំណើរការហាលម្រេច យើងត្រូវទុកម្រេចជាបណ្តុះអាសន្ននៅក្នុងកន្ទេល ស្បៃនីឡុង តង់ ល្អី សម្ភារៈស្តុកស្អាត ឬមួយសម្ភារៈដែលអាចដាក់ផលិតផលជាអាហារបាន។

**ការជ្រើសរើសគ្រាប់ម្រេច**

ការជ្រើសរើសម្រេចធ្វើក្នុងគោលបំណងជម្រុះនូវកំទេចកំទីផ្សេងៗ គ្រាប់មានពណ៌ខុសគេ គ្រាប់ម្រេចដែលមានទំហំតូច និងយកកាកសំណល់រុក្ខជាតិដែលមិនប្រក្រតីចេញពីម្រេច។

ត្រូវជ្រើសរើសម្រេចក្នុងលក្ខខណ្ឌមានអនាម័យបំផុត ដើម្បីទប់ស្កាត់ការចម្លងអតិសុខុមប្រាណ (លាងសម្អាតសរីរាង្គទាំងអស់ដែលប៉ះម្រេចដូចជាដៃ និងជើង) និងការចម្លងសារជាតុគីមី។

ដើម្បីសម្អាតម្រេចខ្មៅ ផលិតករអាចលាងគ្រាប់ម្រេចដែលទើបប្រឡេះរួច ឬម្រេចខ្មៅស្ងួតក្នុងទឹកយ៉ាងយូរបំផុត ៥នាទី។

**ការស្តុក**

ត្រូវស្តុកផលិតផលម្រេចនៅកន្លែងមានខ្យល់ចេញចូល មានដំបូលការពារពន្លឺថ្ងៃ និងសំណើម។ ហាមមិនឱ្យដាក់ម្រេចប៉ះផ្ទាល់ទៅនឹងដី និងដាក់កន្លែងដែលអាចការពារបាននូវរាល់ការចម្លងសារធាតុគីមី និងអតិសុខុមប្រាណ (តាមរយៈសត្វស្រុក កណ្តុរ ។ល។)

**៦.២.៣ ការកែច្នៃ និងវេចខ្ចប់**

ការកែច្នៃផលិតផលពាក់កណ្តាលសម្រេច រួមមាន៖

- ការជ្រើសរើសចុងក្រោយ (គោលបំណងដើម្បីឱ្យម្រេចកំពតមានលក្ខណៈដូចមានចែងក្នុងជំពូកទី ៤ខាងលើ)
- **តារាងទី ២៖** ការពិពណ៌នាអំពី ដំណើរការនៃការកែច្នៃផលិតផលម្រេចជ្រក់ និងសម្ងួត

| ប្រភេទ | គ្រឿងផ្សំ | វិធីសាស្ត្រក្នុងការផលិត | | សុពលភាពនៃផលិតផល |
|---|---|---|---|---|
| | | ដំណាក់កាលទី១ | ដំណាក់កាលទី២ | |
| ជ្រក់ម្រេចខ្ចី (ស្ងួត) | - គ្រាប់ម្រេចខ្ចីស្រស់<br>- អំបិលម៉ដ្ឋ ឬផ្កាអំបិល<br>- ទឹកខ្មេះ<br>- ទឹកអំបិល | - លាងសម្អាតគ្រាប់ម្រេចជាមួយទឹកស្អាត<br>- ដាក់សំដិលគ្រាប់ម្រេចឱ្យស្ងួតទឹក<br>- ប្រឡាក់អំបិល ឬផ្កាអំបិល ឬទឹកអំបិល ឬត្រាំទឹកខ្មេះ<br>- រក្សាទុកយ៉ាងយូរ ៥សប្តាហ៍ រួចយកគ្រាប់ម្រេចដាក់ហាលសម្ងួត | - យកម្រេចខ្ចីស្រស់នៅដំណាក់កាលទី១ ៨០% ទៅ ៩០% ប្រឡាក់អំបិល ឬផ្កាអំបិលពី ១០% - ២០%<br>- សម្ងួត (សំដិល) ពី ៣-៥ ថ្ងៃ<br>- រើសសម្រាំងម្តងទៀត<br>- រួចវេចខ្ចប់ | យ៉ាងយូរ ២ឆ្នាំ ក្រោយពីការវេចខ្ចប់ |
| ជ្រក់ម្រេចខ្ចី (សើម) | - គ្រាប់ម្រេចខ្ចីស្រស់<br>- អំបិល ឬផ្កាអំបិល | - លាងសម្អាតគ្រាប់ម្រេចជាមួយទឹកស្អាត រួចស្រុះទឹកក្តៅ រួចដាក់សំដិលគ្រាប់ម្រេចឱ្យស្ងួតទឹក<br>- បន្ទាប់មកយកគ្រាប់ម្រេចដែលបានសម្អាតរួច (៨០% ទៅ ៨៥%) ប្រឡាក់ជាមួយផ្កាអំបិល ឬអំបិលម៉ត់ (១៥% ទៅ ២០%)។<br>- រក្សាទុកយ៉ាងតិច ២៤ម៉ោង<br>- រួចច្រកចូលក្នុងដប កែវ ឬថង់ប្លាស្ទិក រួចបឺតខ្យល់ចេញ | | យ៉ាងយូរ ២ ឆ្នាំ ក្រោយពីការវេចខ្ចប់ |
| ម្រេចក្រហមជ្រក់(ស្ងួត) | -គ្រាប់ម្រេចក្រហមស្រស់<br>-អំបិល ឬផ្កាអំបិល | - លាងសម្អាតគ្រាប់ម្រេចជាមួយទឹកស្អាត<br>- ដាក់សំដិលគ្រាប់ម្រេចឱ្យស្ងួតទឹក<br>- ប្រឡាក់អំបិល ឬផ្កាអំបិល<br>- រក្សាទុកយ៉ាងយូរ ៥សប្តាហ៍ រួចយកគ្រាប់ម្រេចដាក់ហាលសម្ងួត | -យកម្រេចខ្ចីស្រស់នៅដំណាក់កាលទីមួយ ៨០% ទៅ ៩០% ប្រឡាក់អំបិល ឬ ផ្កាអំបិលពី ១០% - ២០%<br>-សម្ងួត(សំដិល) ពី ៣-៥ថ្ងៃ<br>-កិនបំបែកគ្រាប់ម្រេច ឬរក្សាទាំងមូល | យ៉ាងយូរ ២ឆ្នាំ ក្រោយពីការវេចខ្ចប់ |

| ប្រភេទ | គ្រឿងផ្សំ | វិធីសាស្ត្រក្នុងការផលិត | | សុពលភាពនៃផលិតផល |
|---|---|---|---|---|
| | | ដំណាក់កាលទី១ | ដំណាក់កាលទី២ | |
| | | | -រើសសម្រាំងម្តងទៀត<br>-រួចវេចខ្ចប់ | |
| ម្រេចក្រហមជ្រក់(សើម) | - គ្រាប់ម្រេចក្រហមស្រស់<br>- អំបិល ឬផ្កាអំបិល | - លាងសម្អាតគ្រាប់ម្រេចជាមួយទឹកស្អាត រួចស្រុះទឹកក្តៅ រួចដាក់សំដិលគ្រាប់ម្រេចឱ្យស្ងួតទឹក<br>- បន្ទាប់មកយកគ្រាប់ម្រេចដែលបានសម្អាតរួច ( ៨០% ទៅ ៨៥%) ប្រឡាក់ជាមួយផ្កាអំបិល ឬអំបិលម៉ត់ ( ១៥% ទៅ ២០%)<br>- រក្សាទុកយ៉ាងតិច ២៤ម៉ោង<br>- រួចច្រកចូលក្នុងដប កែវ ឬថង់ប្លាស្ទិក រួចបឺតខ្យល់ចេញ | | យ៉ាងយូរ ២ឆ្នាំ ក្រោយពីការវេចខ្ចប់ |
| ម្រេចខ្ចីសម្ងួត | គ្រាប់ម្រេចខ្ចីស្រស់ (គ្រាប់ម្រេចខ្ចី ១០០%) | យកគ្រាប់ម្រេចទៅស្ងោរ និងទុកឱ្យស្រស់ទឹកល្អ រួចសម្ងួតដោយម៉ាស៊ីនសម្ងួត ជាការស្រេច | | យ៉ាងយូរ ៣ឆ្នាំ ក្រោយពីការវេចខ្ចប់ |
| | ជ្រក់ម្រេចខ្ចី (ស្ងួត) ដែលសម្រេចបាននៅដំណាក់កាលទីមួយ (គ្រាប់ម្រេចខ្ចីជ្រក់ ១០០%) | សម្ងួតដោយម៉ាស៊ីនសម្ងួត | | យ៉ាងយូរ ៣ឆ្នាំ ក្រោយពីការវេចខ្ចប់ |
| ម្រេចក្រហមជ្រក់សម្ងួត | ម្រេចក្រហមជ្រក់(ស្ងួត) ដែលសម្រេចបាននៅដំណាក់កាលទី១ (គ្រាប់ម្រេចក្រហមជ្រក់ ១០០%) | សម្ងួតដោយម៉ាស៊ីនសម្ងួត | | យ៉ាងយូរ ៣ឆ្នាំ ក្រោយពីការវេចខ្ចប់ |

- **ការវេចខ្ចប់៖** ការវេចខ្ចប់ផលិតផលម្រេចសម្រាប់អ្នកប្រើប្រាស់ ត្រូវធ្វើនៅក្នុងសម្ភារៈណីតប្រើប្រាស់សម្រាប់ផលិតផលអាហារ ជាសម្ភារៈថ្មី និងមិនមានអន្តរកម្មជាមួយម្រេច។

**រយៈពេលអតិបរិមា ដែលអាចប្រើប្រាស់ម្រេចបានគឺ៖**

- **ម្រេចខ្មៅ ក្រហម និង ស៖** អាចប្រើប្រាស់បានក្នុងរយៈពេលយ៉ាងយូរ ៥ឆ្នាំ ដោយគិតចាប់ពីរដូវប្រមូលផលម្រេចកំពតត្រូវបានបញ្ចប់ (ថ្ងៃទី៣១ ខែកក្កដា)។
- **ម្រេចម៉ដ្ឋ (ខ្មៅ ក្រហម និង ស)៖** អាចប្រើប្រាស់បានយ៉ាងយូរ ១ឆ្នាំ បន្ទាប់ពីកិនរួច។
- **ម្រេចខ្ចីស្រស់៖** អាចប្រើប្រាស់បានយ៉ាងយូរ ៧ថ្ងៃ បន្ទាប់ពីប្រមូលផលរួច។
- **ម្រេចខ្ចីស្រស់ត្រាំទឹកអំបិល ឬទឹកខ្មេះ៖** អាចប្រើប្រាស់បាន ២ឆ្នាំ បន្ទាប់ពីវេចខ្ចប់រួច។
- **ជ្រក់ម្រេចខ្ចី និងជ្រក់ម្រេចក្រហម(សើម)៖** អាចប្រើប្រាស់បាន ២ឆ្នាំ បន្ទាប់ពីវេចខ្ចប់រួច។

- **ជ្រក់ម្រេចខ្ចី និងជ្រក់ម្រេចក្រហម(ស្ងួត)៖** អាចប្រើប្រាស់បាន ២ឆ្នាំ បន្ទាប់ពីវេចខ្ចប់រួច។
- **ម្រេចខ្ចីសម្ងួត និងម្រេចក្រហមជ្រក់សម្ងួត៖** អាចប្រើប្រាស់បាន ៣ឆ្នាំ បន្ទាប់ពីវេចខ្ចប់រួច។

ការវេចខ្ចប់ **"ម្រេចកំពត"** ត្រូវមានស្លាកសញ្ញា និងបង្ហាញលេខឡូត៍ជាមួយនឹងកាលបរិច្ឆេទកំណត់ការប្រើប្រាស់ ឬកាលបរិច្ឆេទនៃការវេចខ្ចប់។ ការវេចខ្ចប់ **"ម្រេចកំពត"** អាចធ្វើនៅតំបន់ណាក៏បាន ទាំងនៅក្នុងប្រទេសកម្ពុជា ឬអន្តរជាតិ។



**ការសម្រាំងគ្រាប់ម្រេចម្រេច**

## ៧. ការបង្ហាញភស្តុតាងទាក់ទងទៅនឹងទឹកដី

ផលិតកម្មម្រេចនៅក្នុងប្រទេសកម្ពុជា ត្រូវបានពិពណ៌នានៅក្នុងឯកសារចំណាស់មួយរបស់ជនជាតិចិន គឺលោក **ជីវតាខ្វាន់** នៅសតវត្សទី ១៣។ ម្រេចបានចូលមកក្នុងប្រទេសកម្ពុជា និងរីកដុះដាលដំបូងនៅក្នុងខេត្តកំពត គឺចាប់ផ្តើមពីសតវត្សទី១៩ និងរីកដុះដាលខ្លាំងនៅពាក់កណ្តាលសតវត្សទី២០។ នៅពេលនោះហើយដែលឈ្មោះ **"ម្រេចកំពត"** មានភាពល្បីល្បាញ។ គេស្គាល់ **"ម្រេចកំពត"** សាជាថ្មីនៅក្នុងប្រទេសបារាំង។ ក្នុងពេលនោះ រាល់ឯកសារដែលទាក់ទងនឹងផលិតកម្មម្រេចត្រូវបានផ្តល់ទៅឱ្យតំបន់កំពត។ **"ម្រេចកំពត"** ត្រូវបានគេទទួលស្គាល់ថាជាម្រេចដែលមានគុណភាពខ្ពស់សម្រាប់សហគមន៍ចុងភៅនៅក្នុងប្រទេសបារាំង និងអឺរ៉ុប។

ប្រវត្តិ និងកេរ្តិ៍ឈ្មោះ **"ម្រេចកំពត"** បានបង្ហាញក្នុងឯកសាររបស់លោក លុច ម៉ូ ហ្សី ណោ (a respected geographer and historian of Kampot region) ដែលមានភ្ជាប់នៅក្នុងពាក្យស្នើសុំចុះបញ្ជី **"ម្រេចកំពត"**។

ទាក់ទងនឹងមរតកជាប្រវត្តិសាស្ត្រ និងវប្បធម៌នេះ លក្ខណៈពិសេសរបស់ **"ម្រេចកំពត"** មានទំនាក់ទំនងនឹងលក្ខខណ្ឌកត្តាបរិស្ថាននៃតំបន់ ជាពិសេសឥទ្ធិពលនៃអាកាសធាតុ។ ដោយសារវានៅជិតមាត់សមុទ្រ ដូច្នេះសីតុណ្ហភាព និងកម្ពស់ទឹកភ្លៀងទទួលរងឥទ្ធិពលពីសមុទ្រ។ ម្យ៉ាងវិញទៀតតំបន់នេះមានដីសម្រោះទឹកល្អ។

### បច្ចេកទេសផលិតពិសេស

បច្ចេកទេសផលិត **"ម្រេចកំពត"** ប្រែប្រួលទៅតាមបរិស្ថាននៃតំបន់។ មានបច្ចេកទេសសំខាន់ ២(ពីរ) ទាក់ទងទៅនឹងតំបន់ផលិតកម្ម **"ម្រេចកំពត"** ដូចជា៖

- **ទី ១៖** ការចាក់ដីដើម្បីលើកចំការម្រេចឱ្យខ្ពស់ និងការជីកប្រឡាយព័ទ្ធជុំវិញដើម្បីឱ្យចំការម្រេចសម្រោះទឹកល្អ។
- **ទី ២៖** ការដាក់ជីធៅ និងជីសរីរាង្គទៀងទាត់ក្នុងចំការម្រេច

លក្ខណៈពិសេសរបស់ឯកសារទាំង ២នេះ មានភ្ជាប់នៅក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"ម្រេចកំពត" ដូចខាងក្រោម៖**

- របាយការណ៍ FAO ខែមិថុនា ឆ្នាំ១៩៦៨ បានបង្ហាញបន្ថែមអំពី លក្ខណៈពិសេសនៃបច្ចេកទេសផលិតកម្ម (និងលទ្ធផលតម្លៃផលិតកម្ម) និងគុណភាពខ្ពស់របស់ **"ម្រេចកំពត"** ដោយប្រៀបធៀបទៅនឹងតំបន់ដទៃទៀតដែលប្រើប្រាស់ជីច្រើន (តំបន់ដីក្រហមក្នុងខេត្តកំពង់ចាម)។
- របាយការណ៍ប្រៀបធៀបបច្ចេកទេសផលិតកម្មរវាងតំបន់កំពត និងស្រុកមេមត់ ខេត្តកំពង់ចាម និងស្រុកស្នួលខេត្តក្រចេះ នៅឆ្នាំ២០០៨ រៀបចំដោយលោក អំ ភិរម្យ (មន្ត្រីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) និងលោក ម៉ៅ វណ្ណៈ បុគ្គលិកអង្គការសេដាក។

## ៨. ការត្រួតពិនិត្យ

### ៨.១ ការចុះបញ្ជី និងការទទួលស្គាល់ផលិតករ និងប្រតិបត្តិករ

ដូចមានបញ្ជាក់នៅចំណុច ៥.២ ផលិតករ និងប្រតិបត្តិករត្រូវចុះឈ្មោះជាសមាជិកនៅ "**សមាគមលើកកម្ពស់ម្រេចកំពត**" និងត្រូវបានពិនិត្យវាយតម្លៃទទួលស្គាល់ដោយស្របទៅតាមយថាប្រភេទ ឬលក្ខខណ្ឌតម្រូវ។

រាល់ផលិតករទាំងអស់ត្រូវប្រកាសនូវផ្ទៃដីដាំដុះដែលខ្លួនចង់ផលិត **"ម្រេចកំពត"**។ សមាគមនឹងចុះទៅត្រួតពិនិត្យមើលភាពត្រូវគ្នាជាមួយនឹងលក្ខខណ្ឌតម្រូវនៃទំនិញសម្គាល់ភូមិសាស្ត្រ។

**ឧទាហរណ៍ដូចជា៖**

- ទីតាំងចំការស្ថិតនៅក្នុងតំបន់ដែលបានកំណត់ និង
- ដីដាំដុះមានលក្ខណៈស្របគ្នាជាមួយលក្ខណៈដែលបានកំណត់នៅក្នុងចំណុច ៦.១ខាងលើ

រាល់ផលិតករទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចសន្យាប្តេជ្ញាចិត្ត និងត្រូវបានគេពិនិត្យពិច័យយ៉ាងតិច ១ឆ្នាំ មុននឹងទទួលស្គាល់ជាសមាជិកសមាគម។

រាល់ប្រតិបត្តិករទាំងអស់ត្រូវរក្សាឯកសារមួយចំនួននៅផ្ទះរបស់ខ្លួនដូចជា៖ លក្ខន្តិកៈសមាគម កិច្ចសន្យា បញ្ជីគណនីផលិតផល និងសៀវភៅបន្ទុកជាដើម។

### ៨.២ ការត្រួតពិនិត្យចំពោះការប្រតិបត្តិតាមសៀវភៅបន្ទុក

ការត្រួតពិនិត្យរបស់សមាគមលើកកម្ពស់ម្រេចកំពតមាន ២(ពីរ)របៀប គឺ៖ ត្រួតពិនិត្យផ្ទៃក្នុង និងខាងក្រៅ ហើយផលិតករ និងប្រតិបត្តិករមិនអាចបដិសេធការត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យផ្ទៃក្នុង ឬខាងក្រៅ ឬទៅលើមធ្យោបាយរបស់វាបាននោះទេ។ ពួកគាត់មិនអាចបដិសេធច្រើនជាង ១លើក ចំពោះកម្មវិធីនៃការត្រួតពិនិត្យឡើយ។

#### ៨.២.១ ការត្រួតពិនិត្យបច្ចេកទេសផលិត

ការត្រួតពិនិត្យធ្វើឡើងដោយមិនបានប្រកាសប្រាប់ផលិតករ ឬប្រតិបត្តិករជាមុន ដើម្បីត្រួតពិនិត្យទៅលើការប្រតិបត្តិតាមប្រព័ន្ធផលិតកម្ម (ការស្តុកទុក បច្ចេកទេសក្រោយប្រមូលផល ការវេចខ្ចប់។ល។) **"ម្រេចកំពត"** ជាមួយសៀវភៅបន្ទុក។

#### ៨.២.២ ការត្រួតពិនិត្យមើលផលិតផល

ការត្រួតពិនិត្យតាមរយៈការយកសំណាកម្រេចពីផលិតករ ឬប្រតិបត្តិករ ដើម្បីត្រួតពិនិត្យទៅលើការប្រតិបត្តិតាមប្រព័ន្ធផលិតកម្ម **"ម្រេចកំពត"** ជាមួយសៀវភៅបន្ទុក។

មុននឹងដឹក **"ម្រេចកំពត"** ដែលមានបរិមាណច្រើនជាង ២០០គ.ក្រ ចេញពីតំបន់ផលិតកម្ម **"ម្រេចកំពត"** សមាជិកសមាគមត្រូវជូនដំណឹងដល់សមាគម។ ម្រេចទាំងនោះអាចដឹកចេញក្រោយរយៈពេល ៧២ម៉ោង បន្ទាប់ពីសមាជិកសមាគមបានបញ្ចូលព័ត៌មានជាផ្លូវការដល់សមាគម ដើម្បីឱ្យសមាគមពិនិត្យ និងបញ្ជាក់ពីប្រភពដើមរបស់ម្រេចទាំងនោះ។

ការត្រួតពិនិត្យធ្វើឡើងតាមរយៈការយកសំណាកពីផលិតករ ឬប្រតិបត្តិករ ដើម្បីវិភាគលក្ខណៈ **"ម្រេចកំពត"**។ នៅក្នុងដំណើរការត្រួតពិនិត្យផ្ទៃក្នុង គណៈកម្មការត្រួតពិនិត្យដោយញាណ ត្រូវវិភាគឡូត៍របស់ប្រតិបត្តិករ ឬក្រុមហ៊ុន ដែលជាអ្នកវេចខ្ចប់យ៉ាងតិច ៥ឡូត៍ ក្នុង១ឆ្នាំ សម្រាប់សមាជិកនីមួយៗ។

ចំពោះការត្រួតពិនិត្យពីខាងក្រៅ អាចធ្វើការវិភាគដោយញ្ញាណក្នុងករណីចាំបាច់។ គណៈកម្មការវិភាគដោយញ្ញាណត្រូវតែឆ្លងកាត់ការបណ្តុះបណ្តាល។

### ៨.៣ គណនេយ្យ និងការស្វែងរកតឹកដាន

រាល់ផលិតករ និងប្រតិបត្តិករដែលស្ថិតនៅក្នុងចង្វាក់ផលិតកម្ម ត្រូវតែរក្សាទុកបញ្ជីគណនីផលិតផល **"ម្រេចកំពត"** (បរិមាណផលិត និងលក់ ការទិញចូល និងការលក់ចេញ។ល។) ដើម្បីទុកជាឯកសារនៅពេលមានការត្រួតពិនិត្យ និងដើម្បីប្រកាសពីបរិមាណផលិតផលរបស់ខ្លួនក្នុងរយៈពេល ១ឆ្នាំ។

បន្ថែមពីនេះទៀត យន្តការនៃការស្វែងរកតឹកដាន ត្រូវបានរៀបចំដើម្បីអាចតាមដាននូវរាល់បរិមាណសរុប និងដើម្បីកំណត់ថាម្រេចផលិតចេញមកពីទីកន្លែងណាមួយច្បាស់លាស់។

### ៨.៤ ទណ្ឌកម្ម

ផលិតផលដែលមិនបំពេញលក្ខណៈស្របទៅតាមសៀវភៅបន្ទុក នឹងមិនត្រូវអនុញ្ញាតឱ្យលក់នៅលើទីផ្សារ ដោយប្រើឈ្មោះ **"ម្រេចកំពត"** ឡើយ។

វិធានការកែតម្រូវទាំង ២(ពីរ) និង/ឬ ការដាក់ទណ្ឌកម្មអាចត្រូវអនុវត្តចំពោះប្រតិបត្តិករដែលមិនអនុវត្តទៅតាមសៀវភៅបន្ទុក ឬចំពោះអ្នកដែលមិនបានធ្វើបញ្ជីត្រឹមត្រូវទុកសម្រាប់ការត្រួតពិនិត្យ។

កម្រិតទណ្ឌកម្មត្រូវបានសម្រេចចិត្តដោយសមាគម។ បញ្ជីដាក់ទណ្ឌកម្ម គឺជាសៀវភៅកាតាឡុក (វត្ថុវលី) នៃកាដាក់ទណ្ឌកម្ម។ រាល់ការដាក់ទណ្ឌកម្មទាំងអស់ ត្រូវបានរៀបចំឡើងតាមកម្រិតនៃការដាក់ទណ្ឌកម្មចាប់ពីកម្រិតស្រាលបំផុត រហូតដល់កម្រិតធ្ងន់បំផុត។ កម្រិតនៃការពិន័យត្រូវបានសម្រេចចិត្តដោយសមាគម ឬដាក់ពាក្យស្នើសុំដោយអ្នកចេញវិញ្ញាបនបត្រ។ អ្នកត្រួតពិនិត្យខាងក្រៅអាចសម្រេចចិត្តដោយខ្លួនឯងដើម្បីដាក់ទណ្ឌកម្ម ដោយស្របទៅតាមព័ត៌មានដែលទាក់ទងទាំងអស់ ឬទៅតាមលទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុង។ សមាគមអាចចាត់វិធានការណ៍ជាបណ្តោះអាសន្នទៅតាមលទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុង។

អ្នកត្រួតពិនិត្យខាងក្រៅមានអំណាចក្នុងការសម្រេចចិត្ត និងអនុវត្តទណ្ឌកម្ម ប៉ុន្តែសមាគមអាចអនុវត្តទណ្ឌកម្មកម្រិត ១ (អប់រំទូន្មាន ឬណែនាំ) និងកម្រិត ២ (ព្រមាន) ដោយខ្លួនឯង ហើយចាត់វិធានការជាបណ្តោះអាសន្នដោយដាក់ទណ្ឌកម្មកម្រិត ៣ (ទាត់ចោលឡូត៍ទាំងមូល) រហូតដល់មានអន្តរាគមន៍ពីអ្នកត្រួតពិនិត្យពីខាងក្រៅ។

ចំពោះការរំលោភបំពានធ្ងន់ធ្ងរ អាចនាំឱ្យមានការបណ្តេញផលិតករ ឬប្រតិបត្តិករចេញពី **"សមាគមលើកកម្ពស់ម្រេចកំពត"** នឹងអាចដាក់ទោសដោយស្របទៅតាមច្បាប់ស្តីពី **" ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ"** របស់ព្រះរាជាណាចក្រកម្ពុជា។

### ៨.៥ ការអនុវត្តការត្រួតពិនិត្យ

សមាគមអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធ្វើការពិនិត្យមើលការអនុវត្តតាមសៀវភៅបន្ទុករបស់សមាជិកសមាគម។

សមាគមត្រូវចុះកិច្ចសន្យាជាមួយអង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យ ដែលជាអាជ្ញាធរសាធារណៈមានសមត្ថកិច្ច ឬអង្គភាពឯកជនដែលទទួលស្គាល់ផ្លូវការដោយអង្គការស្តង់ដារអន្តរជាតិ ឬស្ថាប័នណាមួយដែលមានប្រព័ន្ធត្រួតពិនិត្យអាចជឿជាក់បាន ដើម្បីត្រួតពិនិត្យខាងក្រៅ និងចេញវិញ្ញាបនបត្រឱ្យផលិតផល **"ម្រេចកំពត"**។

## ៩. ស្លាកសញ្ញា ឬឃីហោផលិតផល "ម្រេចកំពត"

ស្លាកសញ្ញា **"ម្រេចកំពត"** អាចដាក់ឈ្មោះ **"ម្រេចកំពត"** ជាភាសាខ្មែរ និងភាសាដទៃទៀត។ ចំពោះទំហំរបស់វាអាចធំ ឬធំបំផុតបើប្រៀបធៀបជាមួយអក្សរដទៃទៀតនៅក្នុងស្លាកសញ្ញា។ ចំពោះពាក្យ **"ម៉ាកម្គាល់ភូមិសាស្ត្រទំនិញ"** អាចដាក់នៅជិតឈ្មោះ **"ម្រេចកំពត"** ជាភាសាដូចគ្នាទៅនឹង **"ម្រេចកំពត"**។

**ស្លាកឃីហោដែលអាចមើលឃើញ រួមមាន៖**

- ចំណែកនៃស្លាកសញ្ញាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"ម្រេចកំពត"**
- រូបសញ្ញាជាតិសម្រាប់បញ្ជាក់លើគ្រប់មុខទំនិញសម្គាល់ភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា
- អាចដាក់ស្លាកសញ្ញាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ប្រទេស ឬមួយក្រុមប្រទេសផ្សេងទៀតដែល **"ម្រេចកំពត"** បានចុះបញ្ជីការពារជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ប្រសិនបើមាន។

ក្នុងករណីមិនមានលេខឡូតិ៍នៅលើសំបកវេចខ្ចប់ ប្រតិបត្តិករអាចដាក់លេខឡូតិ៍នៅលើស្លាកសញ្ញាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"ម្រេចកំពត"** ដើម្បីជាជំនួយសម្រាប់ធ្វើឱ្យប្រាកដដល់ការស្វែងរកតឹកដាននៃផលិតផល ក្នុងករណីដែលវាមិនមានលើកញ្ចប់នៅលើស្លាកសញ្ញាពិសេស។

សមាជិកសមាគមទាំងអស់ត្រូវប្រើប្រាស់ស្លាកសញ្ញា **"ម្រេចកំពត"** ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៩។

### ចំណុចដែលបានកែប្រែពេលកន្លងមក

| ល.រ | ខ្លឹមសារដើម | ខ្លឹមសារថ្មី | ចំណុច | កាលបរិច្ឆេទ |
|---|---|---|---|---|
| ១. | | | | |
| ២. | | | | |
| ៣. | | | | |
| ៤. | | | | |

**Kingdom of Cambodia**
**Nation Religion King**

# BOOK OF REQUIREMENT
# GEOGRAPHICAL INDICATION PRODUCT
## "Kampot Pepper"

**Prepared by: Kampot Pepper Promotion Association**

**Kampot Province, 27th of February 2023**

# BOOK OF REQUIREMENT OF "KAMPOT PEPPER"

## I. GI APPLICANT

- **Kampot Pepper Promotion Association (KPPA)**
- Registered by Ministry of Interior No.: 293 on the 12th of December 2008
- Address: Angkor Chey I Village, Damnak Kantuot Khang Tboung Commune, Kampong Trach District, Kampot Province
- Telephone No.: 092 75 25 72 / 092 618 011
- E-mail: kppa2008@yahoo.com / kppa2008@gmail.com

## II. PRODUCT NAME

- Khmer name: **ម្រេចកំពត**
- English name: **Kampot Pepper**
- French name: **Poivre de Kampot** and
- in any other languages that include the following types of Kampot Pepper:
  - ម្រេចកំពតខ្មៅ in English "Kampot black pepper" and in French "Poivre noir de Kampot"
  - ម្រេចកំពតក្រហម in English "Kampot red pepper" and in French "Poivre rouge de Kampot"
  - ម្រេចកំពតស in English "Kampot white pepper" and in French "Poivre blanc de Kampot"
  - ម្រេចកំពតខ្ចី in English "Kampot green pepper" and in French "Poivre vert de Kampot"

## III. TYPE OF PRODUCT

Spice, Pepper (Berries of *Piper nigrum L.*)

## IV. PRODUCT DESCRIPTION

**"Kampot pepper"** is characterized by its strong (but not **"burning"**) pungency, not aggressive but developing progressively in mouth. Besides the spicy character, its aromatic intensity gives to **"Kampot pepper"** its particular quality.

**"Kampot pepper"** can be produced and marketed in the following types:

- Black pepper, full berries, or ground
- Red pepper, full berries, or ground
- White pepper, full berries, or ground
- Green pepper, full berries, or clusters *(spike)*.



**Black pepper**



**Red pepper**



**White pepper**



**Green pepper**

**Table 01**: Description of the different types of **"Kampot Pepper"**

| Type | Form | Diameter & Density | Color | SMELL | Taste | Tolerance |
|---|---|---|---|---|---|---|
| Black pepper | Dried berries | Diameter ∅ ≥ 4mm<br>Density ≥ 570 g/l | - Dark black<br>- Black<br>- Brown black or grey black | The smell of grain is medium burning | | - Maximum 5% for the size of berries<br>- Less than 2% for the color |
| | Ground black pepper: Piece of dried grain | It is powder but not very powder. It exists in small pieces that we can see | Dark grey and there are black points | The smell of ground pepper is very burning and last long | | |
| Red pepper | Dried berries | Diameter ∅ ≥ 4mm<br>Density ≥ 570 g/l | Brown red or dark red | The smell of grain is medium burning | | - Maximum 5% for the size of berries<br>- Less than 2% for the color |
| | Red ground pepper: Dry ground berries | Berries are ground into small pieces but not fully ground like powder | Light red with white | The smell of ground pepper is very burning and last long | - Spicy<br>- A little bit sweet | |
| | Salted Red pepper: As full berries or ground | Ground salted red pepper: Berries are ground into small pieces but not fully ground like powder | Dark red with white | The smell of ground pepper fragrance is strong | - Salty<br>- Spicy<br>- A little bit sweet | |
| | | Whole berries: Diameter ∅ ≥ 4 mm | Reddish grey | The smell is fragrant, sour, and aroma | - Salty<br>- Spicy<br>- A little bit sweet | Crispy |
| | Pickled Red pepper: Red pepper berries | Diameter ∅ ≥ 4 mm | Light red | The smell of pepper is light | - Spicy<br>- Salty<br>- A little bit sweet | |

| | | | | | | |
|---|---|---|---|---|---|---|
| | Dried pickled red pepper: Red pepper berries | Diameter ∅ ≥ 4 mm | Light red | The smell of pepper is light | - Spicy<br>- Salty<br>- A little bit sweet | |
| White pepper | Dried berries | Diameter ∅ ≥ 3 mm<br><br>Density ≥ 600 g/l | - Grey white with little yellow color or color of the exocarp of soya bean<br>- It is natural color without adding anything to change the color | The smell of grain is medium burning | | - Maximum 5% for the size of berries<br>- Less than 2% for the color |
| | White ground pepper: Dry ground berries | Berries are ground into small pieces but not fully ground like powder | Whitish grey | The smell of the ground pepper is very burning and last long and pepper oil is presented | Very spicy | |
| Green pepper | The whole cluster of fresh berries | Each cluster must have at least 10 grains<br>Diameter ∅ ≥ 3 mm | Dark green | - Herbal green pepper aroma<br>- There is no burning smell when it is the grain<br>- When it is ground, its smell is strong and burning but not last long<br>- No smell of:<br>• Dust<br>• Fungi | | - Maximum 5% for the size of berries<br>- Less than 2% for the color |
| | Salted Green pepper: Green pepper berries mixed with salt flower or ground salt or Vinegar | Diameter ∅ ≥ 3 mm | - Black<br>- Darker black<br>- Light grey soya bean | - The little smell of peppers<br>- Not strong aroma<br>- The smell is sourly strong<br>- The little smell of pickled | - Moderate salty to salty<br>- Spicy<br>- A little bit sour<br>- A little bit sweet | - Crispy<br>- Soft |
| | Pickled Green pepper: Green pepper berries mixed with salt flower or ground salt Or Marinate in Vinegar | Diameter ∅ ≥ 3 mm | - Dark Green<br>- Bright green to yellow<br>- Soya bean color | - Smell of aroma<br>- Smell of pickled<br>- Smell like honey | - Spicy<br>- Creamy tasty<br>- Moderately salty<br>- A little bit sour<br>- A little bit bitter | - Crispy<br>- Soft |
| | Dried green pepper: Dried green berries or pickled/salted green pepper | Diameter ∅ ≥ 3 mm | Green-Yellowish like soya bean | Pepper fragrance is strong | A little bit spicy | - Crispy |

Certified **"Kampot Pepper"** must be sold to the final clients by properly packaged and labeled to avoid fraud.

## V. GEOGRAPHICAL INDICATION AND PROOF OF THE ORIGIN

### 5.1 Geographical area

The delimited geographical area for the production of **"Kampot Pepper"** is in the following districts and cities:

- ▷ Kampong Trach, Dang Tong, Toeuk Chhou, Chhouk and Kampot city of Kampot province
- ▷ Kep city and Damnak Chang Aeur district of Kep province

**PRODUCTION AREA OF "KAMPOT PEPPER"**




